*បណ្ណព័ត៌មានអំពីជំងឺឆ្លង*

# ជំងឺរលាកថ្លើមប្រភេទ B

***ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺឆ្លងដ៏ធ្ងន់ធ្ងរដែលឆ្លងរាលដាលតាមរយៈឈាមឬជាតិទឹកនៃរាងកាយ។ កុមារទាំងអស់ និងមនុស្សពេញវ័យដែលមានគ្រោះថ្នាក់កើតជំងឺនេះ គួរចាក់ថ្នាំបង្ការជំងឺនេះ។ ការរួមភេទដោយប្រើវិធីការពារនិងការប្រើគ្រឿងសម្ភារៈនិងគ្រឿងបរិក្ខារដែលមានការរម្ងាប់មេរោគ មានសារសំខាន់ ក្នុងការបង្ការកុំឲ្យកើតជំងឺនេះ។***

**កែតំរូវចុងក្រោយ៖** ថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2007

## តើជំងឺថ្លើមប្រភេទ B គឺជាអ្វីទៅ?

- ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺថ្លើមដែលបណ្តាលដោយវីរុសមួយហៅថាមេរោគរលាកថ្លើមប្រភេទ B ។ ‘ជំងឺរលាកថ្លើម’ មានន័យថា ‘ការរលាកឬហើមនៃថ្លើម’។
- នៅពេលកើតមានហើយ អ្នកកើតជំងឺនេះនឹងជារើបរើសះស្បើយ និងគ្មានបញ្ហាអ្វីតទៅទៀតទេ; ឬ
- កើតមានជំងឺនេះយ៉ាងរ៉ាំរ៉ៃ។ ជួនកាលអ្នកកើតជំងឺនេះរ៉ាំរ៉ៃត្រូវបានស្គាល់ថាជា ‘អ្នកផ្ទុកមេរោគក្នុងខ្លួន’។
- អ្នកខ្លះដែលមានជំងឺនេះរ៉ាំរ៉ៃ អាចមានបញ្ហាសុខភាពពាក់ព័ន្ធនឹងការកើតជំងឺនេះ ហើយអ្នកខ្លះទៀតនឹងគ្មានបញ្ហានេះទេ។ ថាតើអ្នកណាដែលជាសះស្បើយពីជំងឺនេះឬមានជំងឺនេះរ៉ាំរ៉ៃ គឺផ្អែកជាសំខាន់លើអាយុរបស់អ្នកនោះ៖ ទារកទើបកើតថ្មីចំនួន 90% កុមារអាយុពី 1-5 ឆ្នាំ ចំនួន 20-50% និងកុមារអាយុច្រើនជាងនោះព្រមទាំងជនពេញវ័យចំនួន 1-10% កើតជំងឺនេះរ៉ាំរ៉ៃ។ ជាធម្មតា អ្នកកើតជំងឺរ៉ាំរ៉ៃនេះអាចចម្លងរោគមួយជីវិតបាន ហើយអាចមានជំងឺរលាកថ្លើមតទៅទៀត។ ក្រោយពីពេលជាច្រើនឆ្នាំមក ជំងឺនេះអាចបណ្តាលឲ្យមានផលវិបាកនានា ដូចជាជំងឺថ្លើមក្រិន ឬមហារីកថ្លើមជាដើម។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

- មនុស្សជាច្រើនគ្មានរោគសញ្ញាទាំងឡាយនៅពេលដែលទើបនឹងឆ្លងរោគនេះ។
- នៅពេលមានរោគសញ្ញា ជាធម្មតាវាមានរួមទាំងជំងឺខាន់លឿង (ស្បែកនិងភ្នែកឡើងពណ៌លឿង) ទឹមនោមមានពណ៌ក្រមៅ លាមកមានពណ៌ស្លេកខ្លាំង អស់កម្លាំង ឈឺពោះ មិនឃ្លានចំណីអាហារ ចង្អោរ ក្អួត និងឈឺសន្លាក់ឆ្អឹង។

## តើជំងឺនេះឆ្លងតាមរបៀបណា?

ជំងឺរលាកថ្លើមប្រភេទ B ឆ្លងទៅកាន់អ្នកដទៃនៅពេលដែលឈាមឬវត្ថុរាវនៃរាងកាយ (ឧទាហរណ៍៖ ទឹកមាត់ ទឹកកាម និងជាតិទឹកចេញពីយោនី) ដែលមានវីរុសជំងឺរលាកថ្លើមប្រភេទ B ចូលទៅក្នុងរាងកាយនៃមនុស្សម្នាក់ទៀតតាមរយៈ៖

- ស្បែកមុតដាច់រលាត់
- ភ្នាសកោសិកា
- ផ្លូវឈាមរត់ តាមរយៈការប្រើរួមគ្នានូវគ្រឿងបរិក្ខារចាក់ដែលមានមេរោគ ឬការប្រើម្ជុលក្រោយពីបានប្រើដោយអ្នកកើតជំងឺមុខរបួសមុតដោយម្ជុលចាក់ដែលមិនរម្ងាប់មេរោគ ឬគ្រឿងប្រដាប់មានមេរោគ។

- ការរួមភេទជាមួយអ្នកកើតជំងឺដោយមិនប្រើស្រោមអនាម័យ។
- ជំងឺរលាកថ្លើមប្រភេទ B ក៏អាចឆ្លងពីមាតាដែលកើតជំងឺទៅកាន់ទារកនៅពេលប្រសូតផងដែរ។

## តើអ្នកណាដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

អ្នកមានគ្រោះថ្នាក់ឆ្លងរោគមានរួមទាំង៖

- ដៃគូរួមភេទនៃអ្នកកើតជំងឺ
- អ្នកចាក់គ្រឿងញៀន
- ទារករបស់មាតាដែលកើតជំងឺ
- អ្នកមានដៃគូរួមភេទច្រើននាក់
- បុរសដែលរួមភេទជាមួយបុរសដូចគ្នា
- អ្នកជំងឺតំរងទឹកនោមដែលត្រូវការជំនួយពីម៉ាស៊ីនសំអាតឈាម
- បុគ្គលិកថែទាំសុខភាព
- កូនរបស់អ្នកដែលមានកំណើតនៅក្នុងប្រទេសទាំងឡាយដែលមានអត្រាកើតជំងឺរលាកថ្លើមប្រភេទ B ដ៏ខ្ពស់
- ការប៉ះពាល់នៃសមាជិកក្នុងផ្ទះជាមួយនឹងអ្នកកើតជំងឺរលាកថ្លើមប្រភេទ B
- អ្នកជាប់ពន្ធនាគារ។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

### ការចាក់ថ្នាំបង្ការរោគ

ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ B មានប្រសិទ្ធភាពណាស់ក្នុងការបង្ការមិនឲ្យឆ្លងជំងឺនេះ។ ការចាក់ថ្នាំបង្ការរោគនេះគួរផ្តល់ឲ្យ៖

- កុមារទាំងអស់នៅពេលប្រសូត អាយុពីរខែ បួនខែ និងប្រាំមួយខែ។ ថ្នាំបង្ការរោគត្រូវបានចាក់ឲ្យទារកនៅឯមន្ទីរពេទ្យដែលទារកនោះប្រសូតមក និងដោយវេជ្ជបណ្ឌិតឬមន្ទីរព្យាបាលក្នុងតំបន់លោកអ្នក ជាផ្នែកនៃការចាក់ថ្នាំបង្ការរោគសំរាប់កុមារភាពជាប្រក្រតី។
- កុមារអាយុ 12 ឆ្នាំទាំងអស់ដែលមិនបានចាក់ថ្នាំបង្ការរោគកាលនៅជាទារក។ ថ្នាំបង្ការរោគត្រូវបានផ្តល់ឲ្យនៅសាលាមធ្យមសិក្សា។
- អ្នកដែលប្រើរបស់នៅក្នុងផ្ទះរួមគ្នាជាមួយអ្នកមានជំងឺរ៉ាំរ៉ៃ ឬតាមរយៈការរួមភេទជាមួយនឹងអ្នកមានជំងឺរ៉ាំរ៉ៃ
- បុរសដែលរួមភេទជាមួយបុរសដូចគ្នា
- អ្នកមានជំងឺកាមរោគដែលអាចចម្លងទៅអ្នកដទៃ
- អ្នកចាក់គ្រឿងញៀន
- អ្នកជំងឺតំរងទឹកនោមដែលត្រូវការជំនួយពីម៉ាស៊ីនសំអាតឈាម
- អ្នកដែលទទួលសារធាតុរបស់ឈាមដោយសារតែមានបញ្ហាឈាមមិនកក
- អ្នកមានជំងឺថ្លើមរ៉ាំរ៉ៃ ឬកើតជំងឺរលាកថ្លើមប្រភេទ C
- គេហជននិងបុគ្គលិកនៃកន្លែងសំរាប់អ្នកមានពិការភាពបញ្ញា
- អ្នកជាប់ពន្ធនាគារនិងបុគ្គលិកនៃមន្ទីរពន្ធនាគារ
- បុគ្គលិកថែទាំសុខភាព
- អ្នកអប់សព
- បុគ្គលិកគ្រាអាសន្ន។

### ការបង្ការការឆ្លងរាលដាល

ដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺរលាកថ្លើមប្រភេទ B ៖

- ត្រូវចាក់ថ្នាំបង្ការរោគ

- ត្រូវប្រើស្រោមអនាម័យបើលោកអ្នករួមភេទជាមួយដៃគូរួមភេទថ្មី ឬជាមួយអ្នកកើតជំងឺរលាកថ្លើមប្រភេទ B បើលោកអ្នកមិនបានចាក់ថ្នាំបង្ការរោគទេនោះ
- បើអ្នកមានផ្ទៃពោះ អ្នកគួរធ្វើតេស្តឈាមរកមើលរោគរលាកថ្លើមប្រភេទ B; កូនក្មេងដែលម្តាយមានជំងឺរលាកថ្លើមប្រភេទ B គួរចាក់ថ្នាំបង្ការរោគរលាកថ្លើមប្រភេទ B (HBIG) និងថ្នាំបង្ការរោគក្នុងរង្វង់ពេល 12 ម៉ោង ក្រោយពីប្រសូតមក
- កុំប្រើគ្រឿងបរិក្ខារចាក់ច្របូកច្របល់ជាមួយអ្នកដទៃ
- កុំប្រើច្របូកច្របល់ជាមួយអ្នកដទៃនូវវត្ថុផ្ទាល់ខ្លួនទាំងឡាយដែលមានឈាមប្រឡាក់ (ឧទាហរណ៍៖ កាំបិតកោរពុកមាត់ ឬច្រាសដុសធ្មេញ)
- បើត្រូវការសាក់ឬចោះផ្នែកណាមួយនៃរាងកាយរបស់លោកអ្នក ត្រូវធ្វើឲ្យប្រាកដថា អ្នកដែលធ្វើឲ្យលោកអ្នកប្រើគ្រឿងបរិក្ខារបោះចោលក្រោយប្រើហើយ និងជាគ្រឿងដែលបានរម្ងាប់មេរោគហើយ
- អ្នកគ្មានចាក់ថ្នាំបង្ការរោគដែលប៉ះពាល់អ្នកកើតជំងឺរលាកថ្លើមប្រភេទ B គួរចាក់ថ្នាំ HBIG និងថ្នាំបង្ការរោគឲ្យបានរហ័សតាមលទ្ធភាព ដោយត្រូវធ្វើទៅនៅក្នុងរង្វង់ពេល 72 ម៉ោងសំរាប់ការប៉ះពាល់តាមរយៈឈាម និងនៅក្នុងរង្វង់ពេល 14 ថ្ងៃសំរាប់ការប៉ះពាល់តាមរយៈការរួមភេទ។

បើលោកអ្នកកើតជំងឺនេះ សូម៖

- កុំធ្វើអំណោយឈាម សរីរាង្គ ឬជាលិកា បើលោកអ្នកមានជំងឺរលាកថ្លើមប្រភេទ B
- ប្រាប់វេជ្ជបណ្ឌិតនិងពេទ្យធ្មេញរបស់លោកអ្នកថា លោកអ្នកមានជំងឺនេះ
- ប្រុងប្រយ័ត្នខ្លាំងដើម្បីធានាថា អ្នកដទៃមិនប៉ះឈាមឬវត្ថុរាវនៃរាងកាយរបស់លោកអ្នក។ សូមជូតសំអាតការកំពប់ជាមួយនឹងក្រដាសកន្សែងពោះគោ និងលាងសម្អាតឲ្យបានម៉ត់ចត់ជាមួយសាប៊ូនិងទឹក រហូតទាល់តែគ្មានឃើញស្នាមប្រឡាក់សោះឡើយ។ បើមានឈាមច្រើនប្រឡាក់កំរាលព្រំ លោកអ្នកប្រហែលជាត្រូវសម្អាតវាដោយប្រើសាប៊ូពិសេសសំរាប់ កំរាលព្រំ (shampoo) ឬវិធីសម្អាតដោយចំហាយ (steam clean)។
- គ្របមុខរបួសជាមួយនឹងក្រណាត់រុំរបួសដែលមិនជ្រាបទឹក។
- ប្រើស្រោមអនាម័យក្នុងការរួមភេទជាមួយនឹងដៃគូរួមភេទថ្មី និងជាមួយនឹងដៃគូដែលគ្មានប្រព័ន្ធការពារទប់ទល់រោគនេះ។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

ការធ្វើតេសឈាមអាចបង្ហាញថាតើអ្នកណាមួយបានកើតជំងឺរលាកថ្លើមប្រភេទ B នៅពេលកន្លងមក និងថាតើអ្នកណាមួយកើតជំងឺនេះដ៏រ៉ាំរ៉ៃ។ តេស្តផ្សេងទៀតដូចជាតេស្តអំពីការបំពេញមុខងាររបស់ថ្លើម អាចបង្ហាញថាតើថ្លើមមានការខូចខាតណាដែរឬទេ។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

អ្នកខ្លះអាចទទួលប្រយោជន៍ពីការព្យាបាលពិសេសប្រឆាំងវីរុស។ សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតលោកអ្នកអំពីលទ្ធភាពនៃការព្យាបាល។ អ្នកកើតជំងឺរលាកថ្លើមរ៉ាំរ៉ៃប្រភេទ B គួរថែទាំថ្លើមរបស់ខ្លួន និងចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ A បើគ្មានប្រព័ន្ធការពាររោគទល់នឹងជំងឺនេះរួចហើយទេនោះ។ ការទទួលទានសុរាអាចធ្វើឲ្យជំងឺថ្លើមរបស់លោកអ្នករឹតតែមានភាពធ្ងន់ធ្ងរឡើង។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

ជំងឺរលាកថ្លើមប្រភេទ B ត្រូវបានរាយការណ៍ឲ្យដឹងដោយទាំងវេជ្ជបណ្ឌិតនិងទាំងមន្ទីរពិសោធន៍។ បុគ្គលិកផ្នែកសុខភាពសាធារណៈ (Public Health Unit) អង្កេតករណីថ្មីៗនៃការកើតមានជំងឺនេះ ដើម្បីរកមើលដឹងកត្តាគ្រោះថ្នាក់ និងជួយគ្រប់គ្រងការឆ្លងរាលដាលតទៅទៀត។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW

ដើម្បីទទួលព័ត៌មានបន្ថែម សូមទាក់ទងវេជ្ជបណ្ឌិត ផ្នែកសុខភាពសាធារណៈក្នុងតំបន់ ឬមណ្ឌលសុខភាពសហគមន៍របស់លោក អ្នក។ សូមរកមើលនៅក្រោមពាក្យ *NSW Government* នៅផ្នែកខាងមុខនៃសៀវភៅទូរស័ព្ទ White Pages ។

| តំបន់ទីក្រុង | ទីតាំង | លេខទូរស័ព្ទ | តំបន់ជនបទ | ទីតាំង | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| **Northern Sydney/Central Coast** | Hornsby | 02 9477 9400 | **Greater Southern** | Goulburn | 02 4824 1837 |
| | Gosford | 02 4349 4845 | | Albury | 02 6080 8900 |
| **South Eastern Sydney/Illawarra** | Randwick | 02 9382 8333 | **Greater Western** | Broken Hill | 08 8080 1499 |
| | Wollongong | 02 4221 6700 | | Dubbo | 02 6841 5569 |
| **Sydney South West** | Camperdown | 02 9515 9420 | | Bathurst | 02 6339 5601 |
| **Sydney West** | Penrith | 02 4734 2022 | **Hunter/New England** | Newcastle | 02 4924 6477 |
| | Parramatta | 02 9840 3603 | | Tamworth | 02 6767 8630 |
| **Justice Health Service** | Matraville | 02 9311 2707 | **North Coast** | Port Macquarie | 02 6588 2750 |
| **NSW Department of Health** | Nth Sydney | 02 9391 9000 | | Lismore | 02 6620 7500 |
| **NSW Health: www.health.nsw.gov.au** | | | | | |